00221209

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

A162/III/6

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៨)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ២៨ សីហា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / AUG / 2008
ម៉ោង (Time/Heure): 09:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះលិខិតដែលពាក់ព័ន្ធនឹង សំណើសុំព័ត៌មានអំពីមន្ត្រីច្បាប់ លោក ដេវីដ ប៊យល៍**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 28 / AUG / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke S TUDZINSKY
យុង ផានិត

**សហមេធាវីការពារក្តី**

លោក អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

00221210

A162/III/6

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៨)

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក"** បានទទួលបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ("ជនត្រូវចោទ") ដែលប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពី *សំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និងអត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក* ***ដេវីដ បយល៍*** ("បណ្តឹងឧទ្ធរណ៍")។

## **ជំពូក ១ - សេចក្តីផ្តើម**

១. នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់សំណើសុំព័ត៌មានទាក់ទងនឹងភាពលំអៀង ដែលឃើញច្បាស់ និងអត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក **ដេវីដ បយល៍** ("សំណើ")។

២. សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ("សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត")។

៣. នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តី បានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនជូនអង្គបុរេជំនុំជម្រះ ("សារណាបណ្តឹង ឧទ្ធរណ៍")។

៤. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបរបស់ខ្លួនចំពោះសេចក្តីសន្និដ្ឋានរបស់លោក អៀង សារី ស្តីពីទំនាស់ផលប្រយោជន៍នៃអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ("សេចក្តីសន្និដ្ឋានតប")។

៥. មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

៦. នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៨ បន្ទាប់ពីធ្វើការពិចារណាការយល់ឃើញរបស់ភាគីដែលបាន លើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាន អង្គបុរេជំនុំជម្រះបានសម្រេចធ្វើការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍ នេះ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

៧. អនុលោមតាមមាត្រា ៨(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក សារណាតបរបស់សហមេធាវីការពារក្តីចំពោះសេចក្តីសន្និដ្ឋានតប (“សារណាតប”) ដែល បានដាក់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ នឹងយកមកធ្វើការពិចារណាដើម្បីធ្វើការសម្រេច លើបណ្តឹងឧទ្ធរណ៍នេះ។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

## ១. <u>កាលបរិច្ឆេទកំណត់ដាក់សារណាបណ្តឹងឧទ្ធរណ៍</u>

៨. នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់ខ្លួន សហព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានថា “សារណាបណ្តឹង ឧទ្ធរណ៍ត្រូវបានរារាំងដោយរយៈពេលកំណត់ ដោយសារជនត្រូវចោទបានដាក់សេចក្តីជូន ដំណឹងពីការប្តឹងឧទ្ធរណ៍នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨។ កាលបរិច្ឆេទកំណត់ដាក់សេចក្តីជូន ដំណឹងពីការប្តឹងឧទ្ធរណ៍ត្រូវបានផុតនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ [...] វិធាន ៧៥(១) នៃវិធានផ្ទៃក្នុង តម្រូវឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ក្នុង រយៈពេល ១០(ដប់)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចដែលជាបញ្ហាចោទ។ នៅក្នុង រឿងក្តីនេះ សហចៅក្រមស៊ើបអង្កេតបានចេញលិខិតដែលជាបញ្ហាចោទចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ហើយមន្ត្រីគ្រប់គ្រងសំណុំរឿងបានបញ្ជូនមកមេធាវីជនត្រូវចោទនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៨។ យោងតាមករណីនេះ សេចក្តីជូនដំណឹងពីការប្តឹងឧទ្ធរណ៍បានផុត នៅ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨។”[១]

[១] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចំពោះសារណារបស់លោក អៀង សារី ស្តីពី ទំនាស់ផលប្រយោជន៍លើករណីមន្ត្រីស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ A162/III/2 (“សេចក្តីសន្និដ្ឋានតប”) វាក្យខណ្ឌទី ២៥ និង ២៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៩. នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់ខ្លួន សហមេធាវីការពារក្តីធ្វើការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ខ្លួនទទួលយកបានតាមទម្រង់ ដោយហេតុថា "ខ្លួនមិនត្រឹមធ្វើការជូនដំណឹងដោយផ្ទាល់មាត់ដល់ក្រឡាបញ្ជីរបស់ ក.ស.ច.ស នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២00៨ ប៉ុណ្ណោះទេ ថែមទាំងបានចុះហត្ថលេខានៅក្នុងសៀវភៅចុះបណ្តឹងឧទ្ធរណ៍នៅថ្ងៃនោះទៀត ហេតុដូច្នេះវាជាសេចក្តីជូនដំណឹងពីការប្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរណ៍។"[២]

១០. វិធាន ៧៥(១)នៃវិធានផ្ទៃក្នុងចែងថា:

> ១. លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ គ្រប់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងក្នុងអំឡុងពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា។ [...]
> ២. ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើជាលាយល័ក្ខអក្សរ ប្រគល់ជូនទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវជូនដំណឹងភ្លាមដល់សហចៅក្រមស៊ើបអង្កេត និង ត្រូវរក្សាទុកសំណុំឯកសារទាំងអស់នៃបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ។ ក្រោយពេលទទួលបានបណ្តឹងឧទ្ធរណ៍នេះក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវទទួលបានការជូនដំណឹងភ្លាម។
> ៣. ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតពីថ្ងៃបានទទួលសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច ឬ ដីកា។ ក្នុងកាលៈទេសៈពិសេស រយៈពេលកំណត់នេះអាចពន្យារបាន។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទនៃការទទួលសារណាបណ្តឹងឧទ្ធរណ៍ និង ដាក់សារណាបណ្តឹងឧទ្ធរណ៍ទាំងនោះទៅក្នុងសំណុំរឿងភ្លាម។ ក្រឡាបញ្ជីត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីផ្សេងៗ និង បញ្ជូនច្បាប់ចម្លងនៃសារណាបណ្តឹងឧទ្ធរណ៍នោះទៅឱ្យពួកគេ។

១១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានធ្វើការជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២00៨ ដោយមិនអាចធ្វើការតវ៉ាបាន។ យោងតាមសៀវភៅចុះបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតបាន

---

[២] សារណាតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះ *បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្តឹងប្រឆាំងចំពោះសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លើសំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលំអៀង ដែលឃើញច្បាស់ និងអត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស គឺលោក* ***ឃើរីង ប៊ិយលី*** ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២00៨ A162/III/4 ("សារណាតប") វាក្យខណ្ឌទី ២២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ របស់សហមេធាវីការពារក្តីជាតិរបស់ជនត្រូវចោទ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ វេលាម៉ោងពីរ(២)រសៀល ហើយសៀវភៅចុះបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានចុះហត្ថលេខាដោយម្ចាស់បណ្តឹងឧទ្ធរណ៍។

១២. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីជូនដំណឹងពីការប្តឹងឧទ្ធរណ៍ បានដាក់ក្នុងរយៈពេលដប់(១០)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច ដោយអនុលោមតាមវិធាន៧៥(១)នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សារណាបណ្តឹងឧទ្ធរណ៍បានដាក់នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ ដោយអនុលោមតាមវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

## ២. <u>វិសាលភាពនៃសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ</u>

១៣. សហមេធាវីការពារក្តីធ្វើការសន្និដ្ឋានថា“វិធាន៧៤(៣) នៃវិធានផ្ទៃក្នុងមិនមានបទប្បញ្ញត្តិចែងឱ្យអស់អំពីលក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍ដែលអាចមាន។ [...] ម្យ៉ាងវិញទៀត វិធាន ៧៣ នៃវិធានផ្ទៃក្នុង [...] មិនមែនជាបទប្បញ្ញត្តិដែលមានចែងលក្ខខណ្ឌកំណត់ឡើយ។ វិធាននេះបញ្ញត្តិសមត្ថកិច្ចបន្ថែមប៉ុណ្ណោះ ហើយគ្មានបទប្បញ្ញត្តិចែងកម្រិតសមត្ថកិច្ច អ.ប.ជ [អង្គបុរេជំនុំជម្រះ] លើករណីទាំងឡាយដូចមានលើកឡើងនៅក្នុងនោះឡើយ។”[៣] ដោយផ្អែកលើករណីនេះសហមេធាវីការពារក្តីធ្វើការសន្និដ្ឋានថា “ប្រសិនបើគិតថាយុត្តិធម៌ វាអាចជាការចម្លែកដែលអនុញ្ញាតឱ្យ ក.ស.ព [ការិយាល័យសហព្រះរាជអាជ្ញា] ប្តឹងឧទ្ធរណ៍គ្រប់ដីការបស់ ក.ស.ច.ស [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ប៉ុន្តែកម្រិតសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ។ សិទ្ធិមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមបញ្ចូលទាំងសិទ្ធិទទួលបាន *សមភាពនៃកម្លាំង* ផងដែរ។”[៤] ចំនុចចុងក្រោយ សហមេធាវីការពារក្តីធ្វើ ការសន្និដ្ឋានថា “វិធានផ្ទៃក្នុងមានលក្ខណៈស្រពិចស្រពិលចំពោះករណីដែលថា អង្គបុរេជំនុំជម្រះមិនមានសមត្ថកិច្ចធ្វើចំណាត់ការលើបណ្តឹងឧទ្ធរណ៍គ្រប់ប្រភេទ ដែលត្រូវបានគេប្តឹងប្រឆាំង

[៣] សារណាគប វាក្យខណ្ឌទី ១៧ និង វាក្យខណ្ឌទី ១៨។

[៤] សារណាគប វាក្យខណ្ឌទី ១៩។

00221214

A162/III/6



ចំពោះសេចក្តីសម្រេចទាំងឡាយរបស់ ក.ស.ច.ស។ និយាយក្នុងលក្ខណៈសាមញ្ញ វិធានផ្ទៃក្នុងមិនបានបញ្ញត្តិបដិសេធសមត្ថកិច្ចរបស់ អ.ប.ជ បែបនេះទេ។ ម៉្យាងវិញទៀត ដូចបានលើកឡើងខាងលើ វិធានផ្ទៃក្នុងមិនចែងកំណត់ក្នុងករណីបែបនេះឡើយ។ ក្នុងករណីបទប្បញ្ញត្តិមានលក្ខណៈផ្ទុយទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់លោក អៀង សារី បែបនេះ បទប្បបញ្ញត្តិនេះមិនអាចយកមកអនុវត្តតាមទាំងងងឹតងងុលឡើយ អាចដូចតាមការយល់របស់ ក.ស.ព។”[៥]

១៤. សហព្រះរាជអាជ្ញាលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានតាមទម្រង់ ដោយសារវា “ហួសពីវិសាលភាពនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង។”[៦] យោងតាមសហព្រះរាជអាជ្ញា “វិធាន៧៤(៣) នៃវិធានផ្ទៃក្នុងចែងរៀបរាប់ទាំងអស់នូវប្រភេទដីកាដែលជនត្រូវចោទអាចធ្វើការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន។ វិធាននេះគ្មានគិតទុកការប្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធផ្តល់ព័ត៌មានឡើយ។”[៧]

១៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ៧៣ នៃវិធានផ្ទៃក្នុងចែងថា៖

**យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ**

បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្តីលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ច ដើម្បីពិនិត្យលើ ៖

ក- បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្តីសម្រេច និង កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤ ។

ខ- ពាក្យសុំមោឃៈភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦ និង

គ- បណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១-៥ និង ១១-៦ វិធាន ២៣-៧ និង ២៣-៩ វិធាន ៣៥-៦ និង វិធាន ៣៨ -៣ នៃវិធានផ្ទៃក្នុងនេះ។

---

[៥] សារណាតប វាក្យខណ្ឌទី ២០។

[៦] សេចក្តីសន្និដ្ឋានតប វាក្យខណ្ឌទី ២៤។

[៧] សេចក្តីសន្និដ្ឋានតប វាក្យខណ្ឌទី ២១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

១៦. ក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធ វិធាន ៧៤ នៃវិធានផ្ទៃក្នុងចែងថា៖

**មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ**

១. គ្មានបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបានឡើយ ប្រសិនបើបណ្ដឹងនេះត្រូវបានពិនិត្យ និង សម្រេចរួចហើយដោយអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមការដោះស្រាយភាពខ្វែងយោបល់គ្នាដែលមានចែងនៅក្នុងវិធាន ៧២។

២. សហព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។

៣. ជនត្រូវចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖

ក- ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ខ- ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

គ- ការបដិសេធពាក្យសុំឱ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក។

ឃ- ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ង- ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាន នេះ។

ច- ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ឆ- ការបដិសេធពាក្យសុំឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃៈភាពកិច្ចស៊ើបសួរណាមួយ។ឬ

ជ- ទាក់ទងទៅនឹងវិធានការការពារ។

៤. [...]

១៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ទាំងវិធាន ៧៣(គ) វិធាន ៧៤ នៃវិធានផ្ទៃក្នុង មិនអនុញ្ញាតឱ្យជនត្រូវចោទប្ដឹងឧទ្ធរណ៍ ប្រឆាំងចំពោះសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ។ ដូច្នេះ អនុលោមតាមវិធានទាំងនេះ អង្គបុរេជំនុំជម្រះគ្មានយុត្តាធិការលើបណ្ដឹងឧទ្ធរណ៍នេះទេ។

១៨. ចំពោះការអះអាងអំពីគោលការណ៍សមភាពរវាងព្រះរាជអាជ្ញា និងមេធាវីការពារក្ដី អង្គបុរេ-ជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតសហព្រះរាជអាជ្ញាធ្វើការប្ដឹងឧទ្ធរណ៍ចំពោះគ្រប់*ដីកា*ទាំងអស់។ ដោយសារសេចក្ដីសម្រេចរបស់សហចៅក្រម

A162/III/16

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៨)

ស៊ើបអង្កេត មិនមែនជាដីកា យើងមិនឃើញបង្កើតជាបញ្ហាចំពោះគោលការណ៍សមភាពរវាងព្រះរាជអាជ្ញា និងមេធាវីការពារក្ដីឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ:**

បដិសេធចោលបណ្ដឹងឧទ្ធរណ៍។

**ភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING នីយ ថុល Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន